# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារ

កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារនេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី ០៦ ខែសីហា ឆ្នាំ ២០២០ រវាងលោកស្រី **ភោគ ស្រីទូច** អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០៣០២៤១៨៧៦(០១) ដែលមានតួនាទីជា **នាយកគ្រប់គ្រងទូទៅ** និងជាតំណាងភាគីនិយោជក នៃក្រុមហ៊ុន **បាអាតហ្គក ឯ.ក** ដែលមានអាសយដ្ឋានស្ថិតនៅ **ផ្ទះ១៣ ផ្លូវ ៣៣៧ សង្កាត់ បឹងកក់១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ** ធ្វើជាមួយនិង ៖

**កញ្ញា អ៊ុក ស្រីនាង** កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៦៧៣៤៥១
ដែលមានតួនាទីជាប្រធានផ្នែកគ្រប់គ្រងភោជនីយដ្ឋាន និងជាតំណាងភាគីនិយោជិក នៃក្រុមហ៊ុនខាងលើ ។
**កញ្ញា សាំង ស្រីដែត** កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៨៩៤៧២២
ដែលមានតួនាទីជាអ្នកបញ្ជរទិញ និងជាតំណាងភាគីនិយោជិក នៃក្រុមហ៊ុនខាងលើ ។

ភាគីទាំងពីរបានធ្វើការព្រមព្រៀងគ្នាដូចខាងក្រោម៖

**១-រយៈពេលនៃការព្យួរកិច្ចសន្យាការងារ ៖**

ការព្យួរកិច្ចសន្យាការងារចាប់ពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០២០ ដល់ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ មូលហេតុដោយសារក្រុមហ៊ុនបានទទួលរងនូវផលប៉ះពាល់យ៉ាងអវិជ្ជមានលើផ្នែកហិរញ្ញវត្ថុ ដែលបង្កដោយវីរុស កូវីដ-១៩ ។

**២-ប្រាក់ឧបត្ថម្ភកំឡុងពេលព្យួរកិច្ចសន្យាការងារ ៖**

ភាគីនិយោជក មិនមានផ្តល់ជាប្រាក់ឧបត្ថម្ភអ្វីឡើយ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ ។

ភាគីនិយោជិត មិនទាមទារប្រាក់ឧបត្ថម្ភអ្វីឡើយ ពីនិយោជក ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ ។

**៣-កាលបរិច្ឆេទចូលបម្រើការងារវិញ ៖**

បុគ្គលិកនិយោជិកទាំងអស់ត្រូវត្រឡប់ចូលមកបម្រើការងារវិញ បន្ទាប់ពីរយៈពេលព្យួរកិច្ចសន្យាការងារនេះ ត្រូវបានបញ្ចប់។កិច្ចសន្យានេះត្រូវបានធ្វើឡើងជាពីរ(០២)ច្បាប់ និងមានតម្លៃស្មើគ្នាចំពោះមុខច្បាប់ ដែលសម្រាប់ភាគីនីមួយៗទុកម្នាក់មួយ(០១)ច្បាប់។

ភាគីទាំងពីរបានអាន ព្រមព្រៀងគ្នា និងបានផ្តិតមេដៃ ដើម្បីជាសាក្ខីភាព។

រាជធានីភ្នំពេញថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០

**តំណាងភាគីនិយោជិត**

**កញ្ញា អ៊ុក ស្រីនាង** **កញ្ញា សាំង ស្រីដែត**

**តំណាងភាគីនិយោជក**

BAATGOK CO., LTD.
KINGDOM OF CAMBODIA

**លោកស្រី ភោគ ស្រីទូច**